ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥-០១៤-២៣០ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់សន្ធនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣៣៧ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និង មាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ៨៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួលប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ១២ និងប្រការ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃ កម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៤

# សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងផ្តល់សន្ទនីយភាពក្នុងរូបភាពជាឥណទានវិបារូបន៍ ដល់សមាជិកសភាផាត់ទាត់ជាតិ តទៅនេះហៅថា "សមាជិក" ដើម្បីសម្រួលដល់កង្វះសន្ទនីយភាពចាំបាច់សម្រាប់បំពេញកាតព្វកិច្ចទូទាត់ក្នុងថ្ងៃ ។

**ប្រការ ២.-**

ការផ្តល់ឥណទានវិបារូបន៍ មានគោលដៅធានាការទូទាត់នៅក្នុងថ្ងៃឱ្យប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាពខ្ពស់ ។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសមាជិកដែលមានសាធនភាព ។ សមាជិកត្រូវស្នើសុំឥណទានវិបារូបន៍ជាលាយលក្ខណ៍អក្សរទុកជាមុនពីធនាគារជាតិនៃកម្ពុជា ដោយត្រូវបំពេញនូវឯកសារចាំបាច់ដូចខាងក្រោម៖

- លិខិតស្នើសុំឥណទានវិបារូបន៍សម្រាប់រយៈពេលមួយឆ្នាំ
- កិច្ចសន្យាឥណទានវិបារូបន៍ចំពោះសមាជិក
- កិច្ចសន្យាដាក់ធានាលើឥណទានវិបារូបន៍របស់សមាជិក

**ប្រការ ៤.-**

សមាជិកត្រូវស្នើសុំឥណទានវិបារូបន៍សម្រាប់មួយឆ្នាំម្តង ដោយបង់សោហ៊ុយទម្រង់ការចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ។

កិច្ចសន្យាឥណទានវិបារូបន៍ និងកិច្ចសន្យាដាក់ធានាឥណទានវិបារូបន៍ មានសុពលភាពបីខែ និងត្រូវស្នើសុំបន្តឡើងវិញរៀងរាល់បីខែម្តង ។

**ប្រការ ៥.-**

សមាជិកអាចស្នើសុំឥណទានវិបារូបន៍យ៉ាងតិចស្មើនឹង ៣០% (សាមសិបភាគរយ) នៃការទូទាត់ដែលខ្ពស់ជាងគេនៅថ្ងៃណាមួយក្នុងរយៈពេលបីខែចុងក្រោយមុនពេលស្នើសុំ ។ ទំហំឥណទានវិបារូបន៍ស្មើនឹង ១០០% (មួយរយភាគរយ) នៃតម្លៃដើមនៃវត្ថុធានា ។ ការផ្តល់ឥណទានវិបារូបន៍នេះ នឹងត្រូវអនុវត្តនៅពេលដែលគណនីទូទាត់មានសមតុល្យមិនគ្រប់គ្រាន់សម្រាប់បំពេញកាតព្វកិច្ចទូទាត់ក្នុងថ្ងៃប៉ុណ្ណោះ ដោយសមាជិក ត្រូវស្នើសុំផ្ទេរប្រាក់ពីគណនីចរន្តទៅគណនីទូទាត់ ។

**ប្រការ ៦.-**

វត្ថុធានាសម្រាប់ឥណទានវិបារូបន៍របស់ធនាគារជាតិនៃកម្ពុជាដែលអាចទទួលយកបាន រួមមានវិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់ និងមូលបត្រអាចជួញដូរបាន (NCD) ចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ។

វត្ថុធានាត្រូវមានឥណប្រតិទានវែងជាងឥណប្រតិទានរបស់ឥណទានវិបារូបន៍យ៉ាងតិចចំនួនពីរថ្ងៃនៃថ្ងៃធ្វើការ ។

**ប្រការ ៧.-**

ឥណទានវិបារូបន៍អាចផ្ដល់ជូនជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក ។ ការប្រាក់ត្រូវបានគិតលើចំនួនប្រាក់ដែលបានប្រើប្រាស់ គិតចាប់ពីពេលបានទទួលឥណទាន ក្នុងអត្រាដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៨.-**

ឥណប្រតិទាននៃការប្រើប្រាស់ឥណទានវិបារូបន៍មានរយៈពេលមួយថ្ងៃ ដោយត្រូវសងវិញនៅថ្ងៃបន្ទាប់ជាកំហិត ។ ករណីថ្ងៃសងវិញ ត្រូវចំថ្ងៃសៅរ៍ ឬថ្ងៃឈប់សម្រាកបុណ្យជាតិ កម្រៃការប្រាក់នឹងត្រូវបានគណនាតាមចំនួនថ្ងៃជាក់ស្ដែង ។

**ប្រការ ៩.-**

សមាជិកដែលទទួលបានឥណទានវិបារូបន៍ហើយខកខានមិនបានសងនៅថ្ងៃឥណប្រតិទាន នឹងត្រូវរងពិន័យទ្វេរដងនៃអត្រាការប្រាក់ដែលបានកំណត់ តាមចំនួនថ្ងៃប្រើប្រាស់ជាក់ស្ដែង ។

**ប្រការ ១០.-**

រាល់ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១១.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានប្រតិស្រុតនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១២.-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៤

**ទេសាភិបាល**

ជា.ចាន់តូ

**កន្លែងទទួល៖**

- ដូចប្រការ ១១ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្ដីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"